ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

**មាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរ៤នាក់ ពីម៉ាឡេស៊ី និងស្ត្រីខ្មែរម្នាក់ពីប្រទេសចិន**

------------

I. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៤នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ឈ.ច** អាយុ២៨ឆ្នាំ មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ (២) ពលការិនី **ធ.ច** អាយុ២៩ឆ្នាំ មកពីស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ (៣) ពលករ **ជ.ក.ស** អាយុ២៩ឆ្នាំ មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និង (៤) ពលករ **ធ.ច** អាយុ២៤ឆ្នាំ មកពីស្រុកបាកាន ខេត្តពោធិសាត់។ ពលករ-ពលការិនីទាំង**៤នាក់** បានទៅម៉ាឡេស៊ីខុសច្បាប់ដោយខ្លួនឯង ហើយធ្វើការនៅរោងចក្រផលិតតុ ទូ និងគ្រឿងសង្ហារឹម នៅឆ្នាំ២០១៥។ ដោយចង់ត្រឡប់មកកម្ពុជាវិញ អ្នកទាំង៤ បានទៅស្ថានទូតនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្នើជួយរៀបចំមាតុភូមិនិវត្តន៍។

ស្ថានទូតបានចេញលិខិតធ្វើដំណើរ សម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ព្រមទាំងផ្តល់ការស្នាក់នៅនិងអាហារបរិភោគ ជូនដល់ពួកគេ ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ។

ពលករ-ពលការិនីទាំង**៤នាក់** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** ថ្ងៃទី **១៤** ខែ **មករា ឆ្នាំ២០១៧** វេលាម៉ោង**០៧:៥០**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

II. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ ប្រទេស**ចិន** បានរៀបចំមាតុភូមិនិវត្តន៍ស្ត្រីខ្មែរម្នាក់ឈ្មោះ **យ.ស.ម** អាយុ២៤ឆ្នាំ មកពីស្រុកបាភ្នំ ខេត្តព្រៃវែង ដែលត្រូវបានមេខ្យល់នាំចូលប្រទេសចិនឆ្លងកាត់តាមប្រទេសវៀតណាម ដើម្បីទៅរៀបការជាមួយបុរសជនជាតិចិនក្នុងខេត្តជាំងស៊ី ដោយពុំមានចុះលិខិតអាពាហ៍ពិពាហ៍។ ដោយរស់នៅមិនចុះសំរុងជាមួយប្តី នាងបានស្នើអន្តរាគមន៍ពីស្ថានអគ្គកុងស៊ុលនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៦ ជួយអោយបានត្រឡប់មកកម្ពុជាវិញ។

ស្ថានអគ្គកុងស៊ុល បានសហការជាមួយអាជ្ញាធរទីក្រុងសៀងហៃ និងអាជ្ញាធរខេត្តជាំងស៊ី រៀបចំបែបបទធ្វើដំណើរជូនស្ត្រីរងគ្រោះ ហើយនាងនឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី **១៤** ខែ **មករា** ឆ្នាំ **២០១៧** វេលាម៉ោង០៣:៤៥នាទីទៀបភ្លឺ តាមជើងយន្តហោះK6 867 ៕

ភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ